# Asian Productivity Organization
# "The APO in the News"

Name of publication: LA REINE PEANICH (27 February –4 March 2017, Cambodia)
Page: 4–5

# លោក Joselito Bernado៖ ចង់អភិវឌ្ឍសេដ្ឋកិច្ចបានរហ័ស និងមាននិរន្តរភាពត្រូវផ្តោតលើចំណេះដឹងបច្ចេកវិទ្យា

សហគ្រាសជោគជ័យគឺជាបំណងប្រាថ្នារបស់សហគ្រិនគ្រប់រូប ហើយក៏ជាកត្តាដ៏សំខាន់នៃការទ្រទ្រង់សេដ្ឋកិច្ចប្រទេសឱ្យរីកចម្រើន និងលូតលាស់ទៅមុខផងដែរ ខណៈការរីកចម្រើនទាំងនោះត្រូវការជាចាំបាច់នូវធនធានមនុស្សដែលពូកែ និងមានសីលធម៌។ អង្គការផលិតភាពអាស៊ី (APO) ជាអង្គការជំនាញមួយក្នុងការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យផលិតភាពប្រកបដោយជោគជ័យ ហើយក៏មានសហគ្រាសកម្ពុជាជាច្រើនទទួលបានការបណ្តុះបណ្តាលពីអង្គការនេះទាំងក្នុងកម្រិតជាតិ និងអន្តរជាតិ។

កាលពីពេលថ្មីៗនេះអ្នកយកព័ត៌មាននៃកាសែតឡារ៉ែន ពាណិជ្ជ បានជួបសម្ភាសន៍ លោក Joselito Bernado ប្រធាននាយកដ្ឋានផែនការ និងស្រាវជ្រាវនៃអង្គការផលិតភាពអាស៊ី (APO) ជុំវិញការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការក្នុងនាមប្រទេសជាសមាជិក។

**ជាដំបូងសូមលោកបង្ហាញពីគម្រោងដែលអង្គការ APO បានធ្វើនៅកម្ពុជា ហើយមានបេសកកម្មអ្វីខ្លះក្នុងការកសាងសមត្ថភាពធនធានមនុស្សក្នុងវិស័យផលិតភាព?**

អង្គការផលិតភាពអាស៊ី (APO) បានបង្កើតឡើងក្នុងឆ្នាំ១៩៦១ ដោយមានសមាជិកស្ថាបនិកចំនួន៨ ប្រទេស ហើយរហូតមកដល់ពេលនេះសមាជិកបានកើនដល់១៩ប្រទេសនៅទូទាំងអាស៊ី និងតំបន់ប៉ាស៊ីហ្វិក។ បេសកកម្មរបស់អង្គការ APO គឺជួយប្រទេសជាសមាជិកដើម្បីធ្វើឱ្យបរិយាកាសសេដ្ឋកិច្ចកាន់តែមានភាពល្អប្រសើរ តាមរយៈការលើកកម្ពស់ផលិតភាព។ ដូច្នេះរាល់កម្មវិធីរបស់ APO គឺផ្តោតសំខាន់ទៅលើការគាំទ្រដល់ប្រទេសជាសមាជិកដើម្បីធ្វើឱ្យបរិយាកាសសេដ្ឋកិច្ចមានភាពល្អប្រសើរក្នុងវិស័យមួយចំនួន ជាពិសេសវិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម ហើយថ្មីៗនេះយើងក៏បានបញ្ចូលនូវការធ្វើឱ្យប្រសើរឡើងក្នុងផលិតភាពចំពោះវិស័យសាធារណៈ។ យើងជឿថា តាមរយៈការធ្វើឱ្យប្រសើរឡើងនូវផលិតភាព គឺវានឹងអាចជួយប្រទេសជាសមាជិកឱ្យកាន់តែមានភាពប្រសើរក្នុងវិស័យសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។ វាក៏ត្រូវបានគេជឿថា នឹងជួយពង្រឹងស្ថានភាពរស់នៅរបស់ប្រជាជនផងដែរ។

**តើលោកអាចបង្ហាញពីសកម្មភាពខ្លះៗដែលអង្គការ APO និងកម្ពុជាបានធ្វើការងារជាមួយគ្នានាពេលកន្លងមក? តើអ្វីជាចំណុចជោគជ័យរបស់កម្ពុជាក្នុងការចូលរួមសកម្មភាពជាមួយ APO?**

ប្រទេសកម្ពុជាបានចូលជាសមាជិកអង្គការផលិតភាពអាស៊ី APO ក្នុងនៅឆ្នាំ2002។ កម្ពុជាជាសមាជិកក្មេងខ្ចី ជាមួយប្រទេសឡាវដែលបានចូលជាសមាជិករបស់អង្គការនេះនៅឆ្នាំ2004។ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះយើងបានគាំទ្រកម្ពុជាក្នុងការផ្តល់ការបណ្តុះបណ្តាល និងការអភិវឌ្ឍក្រុមហ៊ុនតូចៗ ជាដើម។ យើងមានរបៀបគាំទ្រជាច្រើនផ្សេងទៀតសម្រាប់កម្ពុជា ដូចជាការបញ្ជូនជំនាញការសម្រាប់ការបណ្តុះបណ្តាល ជាក់ស្តែងក្នុងសន្និសិទជាតិនាពេលនេះស្តីពីការផ្តល់ផលិតភាពដោយគំនិតច្នៃប្រឌិត ជាសកម្មភាពមួយដែលយើងតែងផ្តល់ដល់ប្រទេសជាសមាជិករបស់យើងផងដែរ។

**តើលោកបានបម្រើការងារឱ្យអង្គការ APO រយៈពេលប៉ុន្មានហើយ?**

ខ្ញុំបានចូលរួមការងារជាមួយអង្គការ APO រយៈពេល12ឆ្នាំមកហើយ។ ខ្ញុំបានចាប់ផ្តើមដំបូងជាមួយនាយកដ្ឋានកសិកម្មនៃអង្គការ APO ហើយខ្ញុំបានកាន់តួនាទីជាប្រធាននាយកដ្ឋានកសិកម្មក្នុងរង្វង់4-5ឆ្នាំចុងក្រោយ មុនពេលខ្ញុំប្តូរទៅកាន់តួនាទីជាប្រធាននាយកដ្ឋានផែនការ និងស្រាវជ្រាវនាមួយឆ្នាំចុងក្រោយនេះ។ ជាមួយអាណត្តិថ្មីនេះ ខ្ញុំមានគំនិតថ្មីៗជាច្រើនដើម្បីគាំទ្រដល់ប្រទេសជាសមាជិកក្នុងវិស័យផលិតភាពជាតិនេះ។

ខ្ញុំបានមកកម្ពុជាដំបូងក្នុងឆ្នាំ2005 ដោយយើងបានរៀបចំសន្និសីទស្តីពីគោលការណ៍ Kaizen និង ស5។ ខ្ញុំពិតជាចាប់អារម្មណ៍មែនទែននាពេលនោះ ដោយសារអ្នកចូលរួមមានរហូតដល់ជាង100នាក់។



ចាប់តាំងពីពេលនោះមក ខ្ញុំបានមកប្រទេសកម្ពុជាស្ទើរតែរៀងរាល់ឆ្នាំ។ រាល់ពេលដែលខ្ញុំមកទីនេះ អ្នកទាំងអស់គ្នាពិតជារាក់ទាក់ និងរីករាយចំពោះអ្វីដែលយើងចង់លើកកម្ពស់។

**តើលោកកត់សម្គាល់ថាមានការរីកចម្រើនថ្មីៗអ្វីខ្លះចំពោះសហគ្រិនកម្ពុជា? បន្ទាប់ពីការចូលរួមកម្មវិធីដែលរៀបចំឡើងដោយអង្គការផលិតភាពអាស៊ី និងមជ្ឈមណ្ឌលផលិតភាពជាតិរបស់កម្ពុជា (NPCC)?**

ពិតហើយក្នុងដំណើរមកកាន់កម្ពុជាដំបូង ខ្ញុំបានទៅទស្សនកិច្ចនៅសិប្បកម្ម លីលីហ្វូត ដែលជាសហគ្រាសតូចមួយដឹកនាំដោយស្ត្រី។ យើងក៏បានផ្តល់នូវអ្នកជំនាញការ ដើម្បីជួយដល់ស្ត្រីរូបនោះក្នុងការរៀបចំសម្ភារឱ្យត្រូវតាមកន្លែងសមរម្យដោយអនុវត្តតាម "វិធីសាស្ត្រ Kaizen និង ស5"។ ពេលវេលាចេះតែកន្លងទៅ ខ្ញុំពិតជាបានឃើញលីលីហ្វូត មានភាពប្រសើរឡើងផ្នែកប្រព័ន្ធអាជីវកម្ម និងគុណភាពផលិតផល ហើយបើតាមខ្ញុំដឹងរហូតដល់ពេលនេះគេអនុវត្តន៍បានល្អប្រសើរមែនទែន!។ខ្ញុំក៏បានទៅទស្សនកិច្ចនៅកន្លែងខ្លះនិងភូមិខ្លះទៀតនៅកម្ពុជា។ ជាក់ស្តែងកាលពីសប្តាហ៍មុននេះ ខ្ញុំបានទៅកម្សាន្តនៅខេត្តព្រះសីហនុ ខ្ញុំពិតជាភ្ញាក់ផ្អើលខ្លាំង ដោយវាហាក់ដូចជាមិនសមថាកម្ពុជាជាប្រទេសក្រីក្រនោះទេ។ អ្នកអាចមើលឃើញនូវស្ថានភាពរស់នៅ ហេដ្ឋារចនាសម្ព័ន្ធ សណ្ឋាគារស្អឹមស្អៃ ហើយខ្ញុំគិតថា រយៈពេលជាង១០ឆ្នាំខាងមុខទៀត កម្ពុជាអាចប្រែក្លាយដូច ហុងកុង ឬក៏ប្រទេសដែលមានការអភិវឌ្ឍល្អនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍នេះ។

**ខ្ញុំចងចាំថា អង្គការផលិតភាពអាស៊ី មជ្ឈមណ្ឌលផលិតភាពជាតិ រួមនឹងក្រសួងទេសចរណ៍ បានរៀបចំសន្និសីទពាក់ព័ន្ធនឹងវិស័យទេសចរណ៍។ តើអ្វីជាខ្លឹមសារសំខាន់សម្រាប់អ្នកពាក់ព័ន្ធ?**

ខ្ញុំបានចាប់ផ្តើមគម្រោងកសិទេសចរណ៍នៅអង្គការផលិតភាពអាស៊ី APO ក្នុងឆ្នាំ2007 ដោយពេលនោះ ខ្ញុំស្ថិតក្នុងនាយកដ្ឋានកសិកម្ម។ ខ្ញុំបានចូលរួមលើកស្ទួយរឿងនេះ ព្រោះវាជាមធ្យោបាយមួយក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូលរបស់ប្រជាកសិករ។ សម្រាប់កម្ពុជា ដែលជាប្រទេសគ្របដណ្តប់ដោយវិស័យកសិកម្ម តើអ្នកដឹងទេថាចំណូលពីការងារកសិកម្មគឺតិចមែនទែន ដូចនេះអ្នកត្រូវតែគិតរកមធ្យោបាយដើម្បីឱ្យកសិករទទួលបានប្រាក់ចំណូលបន្ថែម ហេតុដូច្នេះហើយ កសិទេសចរណ៍អាចជាមធ្យោបាយមួយសម្រាប់អនុវត្ត

ក្នុងការបង្កើនប្រាក់ចំណូល។ មានរូបមន្តជាច្រើន តែខ្ញុំសូមលើកឧទាហរណ៍ខ្លះៗនៃកម្មវិធីកសិទេសចរណ៍នៃខេត្ត អាម៉ូរី របស់ប្រទេសជប៉ុន។ នៅទីនោះគេប្រើប្រាស់សិល្បៈនៅលើវាលស្រែ ដើម្បីទាក់ទាញភ្ញៀវទេសចរ ស្របពេលដែលកសិករមានលទ្ធភាពបង្កើនប្រាក់ចំណូលពីការអភិវឌ្ឍផលិតផលថ្មីៗដែលគេអាចលក់ទៅឱ្យអ្នកទេសចរ។ ដូច្នេះកសិទេសចរណ៍ អាចជាមធ្យោបាយមួយដ៏ល្អក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូលរបស់កសិករ ហើយវាក៏មានប្រយោជន៍ដល់អ្នកទេសចរ ដើម្បីយល់ដឹងពីសុខុមាលភាពរបស់ប្រជាកសិករក្នុងការផលិតអាហារផងដែរ។ ទាំងនេះសុទ្ធតែធ្វើឱ្យទេសចរណ៍មានការកោតសរសើរ ហើយគាំទ្រដល់កសិករ។

**តើការកសាងសមត្ថភាពក្នុងចំណោមសហគ្រិន ជាពិសេសសហគ្រិនក្មេងៗមានសារសំខាន់អ្វីខ្លះ សម្រាប់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចនិង ការអភិវឌ្ឍផ្នែកអាជីវកម្មនៅកម្ពុជា ?**

ខ្ញុំឃើញសក្តានុពលច្រើនណាស់ក្នុងការពង្រីកសេដ្ឋកិច្ចប្រទេសកម្ពុជា ព្រោះកម្ពុជាមានធនធានរុក្ខជាតិ ជាពិសេសដីធ្លីតែម្តង ដែលគេអាចពង្រីកសកម្មភាពដាំដុះ និងទាក់ទាញភ្ញៀវទេសចរ។ ការមានប្រជាជនវ័យក្មេងច្រើន គឺជាសក្តានុពលដ៏មានតម្លៃសម្រាប់កម្ពុជាក្នុងការអភិវឌ្ឍប្រទេសក្នុងថ្ងៃអនាគត។ ដើម្បីធានាដល់និរន្តរភាពនៃស្ថានភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្នទៅក្នុងថ្ងៃអនាគត យើងត្រូវតែកសាងសមត្ថភាពប្រជាជនដើម្បីរួមគ្នាកសាងស្មារតីសហគ្រិន ជាពិសេសផ្តោតលើធនធានមនុស្សវ័យក្មេងដើម្បីឱ្យពួកគេចូលប្រឡូកក្នុងសកម្មភាពអាជីកម្ម។

**តើ APO មានផែនការអ្វីសម្រាប់អនាគតក្នុងការកសាងសមត្ថភាពធនធានមនុស្សក្នុងផលិតភាព ?**

ឥឡូវនេះដើម្បីបង្កើតបាននូវទំនុកចិត្ត គឺយើងបានបង្កើនការយល់ដឹងក្នុងចំណោមអ្នកពាក់ព័ន្ធនៃប្រទេសជាសមាជិកអំពីសារសំខាន់នៃការផ្សាភ្ជាប់គ្នាទៅកាន់សេដ្ឋកិច្ចពិភពលោក។ យើងត្រូវដឹងថា និន្នាការបច្ចុប្បន្ននេះគឺជាសម័យកាល“សេដ្ឋកិច្ចឌីជីថល”។ ប្រទេសជប៉ុនថ្មីៗនេះរដ្ឋាភិបាលបានប្រកាសពីផែនការទាក់ទាញក្នុងវិស័យកម្មន្តសាល ហើយទាំងអស់នោះសុទ្ធតែបានផ្តល់តម្លៃដល់ការប្រើប្រាស់បច្ចេកវិទ្យា។

**ដើម្បីភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅតំបន់ និងពិភពលោក តើអ្វីជាបេសកកម្មរបស់អង្គការ APO ក្នុងការជួយដល់កម្ពុជា ?**

សន្និសីទរៀងរាល់លើករួមទាំងលើកនេះផង គឺជាអ្វីមួយដែលផ្តួចផ្តើមឡើងដោយ APO។ យើងបានព្យាយាមជូនដំណឹងដល់អ្នកពាក់ព័ន្ធ ពិសេសមនុស្សជំនាន់ថ្មី អំពីសារសំខាន់នៃការប្រើប្រាស់បច្ចេកវិទ្យាដែលគេហៅថា ICT។ យើងតែងនាំយកអ្នកជំនាញការពីគ្រប់ជំនាញដើម្បីឆ្លើយតបតាមតម្រូវការរបស់សិក្ខាកាម។ អ្នកខ្លះបានឱ្យតម្លៃលើរឿងធំៗ តែយើងក៏បានឱ្យតម្លៃលើរឿងតូចៗដែរ ដូចជាសហគ្រាសតូចៗ។ យើងឃើញនៅប្រទេសកូរ៉េ សហគ្រាសតូចៗជាច្រើន ដែលមានគ្នាប្រហែល 5នាក់អាចរកចំណូលបានយ៉ាងច្រើន។ នេះជាអ្វីដែលគេត្រូវចាប់ផ្តើម ហើយទទួលការគាំទ្រដោយផ្អែកលើការច្នៃប្រឌិតថ្មី។ សហគ្រាសតូចៗរបស់កូរ៉េជាគំរូល្អមួយ។ យើងក៏បានអញ្ជើញអ្នកជំនាញការពីចក្រភពអង់គ្លេស ដើម្បីចែករំលែកអ្វីដែលចាំបាច់មាននៅចក្រភពអង់គ្លេស ជាពិសេសមជ្ឈមណ្ឌលមួយនៃសាកលវិទ្យាល័យ Cambridge ដើម្បីអាចជួយសហគ្រាសតូចៗ សម្រាប់ជាការចែករំលែកដល់សិក្ខាកាម។

**តើលោកគិតថា ប្រទេសណាដែលមានរបៀបអនុវត្តន៍ល្អ ?**

ពីប្រទេសមួយទៅប្រទេសមួយ មានគំរូផលិតភាពខុសៗគ្នា តែខ្ញុំនៅតែនិយាយថា បើអ្នកមានបំណងរៀបចំផលិតភាពស្របតាមបច្ចេកវិទ្យាថ្មីៗ ខ្ញុំយល់ថា ប្រទេសកូរ៉េជាគំរូល្អ។ កូរ៉េជាប្រទេសតូច ហើយធនធានធម្មជាតិក៏មានកម្រិតដែរ ប៉ុន្តែអ្នកអាចឃើញពីចំណាត់ថ្នាក់ផ្នែកច្នៃប្រឌិតពិតជាខ្ពស់ណាស់ក្នុងពិភពលោក។ កូរ៉េស្ថិតក្នុងចំណោមចំណាត់ថ្នាក់ខ្ពស់ទាំង5ជារៀងរាល់ឆ្នាំ ដោយសារគេសង្កត់ធ្ងន់ទៅលើការវិនិយោគក្នុងការអភិវឌ្ឍលើការងារស្រាវជ្រាវ និងការកសាងសមត្ថភាពរបស់ប្រជាជនរបស់គេ បណ្តុះបណ្តាលប្រជាជនរបស់គេ អំពីរបៀបប្រើប្រាស់បច្ចេកវិទ្យាទំនើបថ្មី ហើយគេព្យាយាមបង្កើតបច្ចេកវិទ្យាថ្មីៗបន្ថែមទៀតដែលអាចបង្កើតប្រាក់ចំណូលសម្រាប់ពួកគេ។

**ជាមួយនឹងបទពិសោធន៍ក្នុងការធ្វើការជាច្រើនជាមួយសហគ្រិនកម្ពុជា តើលោកមានអ្វីខ្លះនិយាយទៅកាន់ពួកគាត់ ?**

បដិវត្តន៍ថ្មីៗក្នុងឧស្សាហកម្មកំពុងបង្កើតនូវបញ្ហាប្រឈមជាច្រើន តែស្របជាមួយគ្នានេះវាក៏បានបង្កើតនូវកាលានុវត្តភាពថ្មីៗជាច្រើនផងដែរ។ នៅពេលយើងគិតអំពីការចាប់ផ្តើម ការចាប់ផ្តើមជាច្រើនបានរីកលូតលាស់ ដូចដែលយើងបានឃើញនៅប្រទេសកូរ៉េ និងសិង្ហបុរី។ សហគ្រិនវ័យក្មេងៗជាច្រើនបានជួយបង្កើតនូវគំនិតអាជីវកម្ម ហើយគេព្យាយាមប្រតិបត្តិឱ្យចេញជារូបរាងនូវគំនិតអាជីវកម្មនោះ ឱ្យទៅជាអាជីវកម្មពិតប្រាកដ ដើម្បីបង្កើតប្រាក់ចំណូល។ ដូចនេះកម្ពុជានៅមានកាលានុវត្តភាពច្រើន ជាពិសេសនៅក្នុងចំណោមមនុស្សវ័យក្មេងៗ ដែលមានគំនិតច្នៃប្រឌិតខ្ពស់ ហើយប្រើប្រាស់ការច្នៃប្រឌិតនោះសម្រាប់បង្កើតឱកាសដើម្បីឱ្យសហគ្រាសមាននិរន្តរភាព និងជោគជ័យ។